# ឯកឧត្តម ចម ប្រសិទ្ធ ជួបនាយកប្រតិបត្តិនៃវិទ្យាស្ថាន **ERIA** ជប៉ុន



នៅព្រឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបលោក **Hidetoshi Nishimura** នាយកប្រតិបត្តិនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ីបូព៌ា និងអាស៊ាន ហៅកាត់ថា **ERIA** ដើម្បីពិភាក្សាការងារនៅទីស្ដីការក្រសួង ។



លោក **Hidetoshi Nishimura** នាយកប្រតិបត្តិនៃវិទ្យាស្ថាន ERIA បានសម្ដែងនូវទឹកចិត្តរីករាយ និងថ្លែងអំណរគុណចំពោះឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដែលឯកឧត្តម បានគាំទ្រយ៉ាងពេញទំហឹង ចំពោះការបង្កើតនិងបេសកកម្មរបស់វិទ្យាស្ថាន ERIA ក្នុងខណៈដែលឯកឧត្តម ធ្វើជាទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

សម្រាប់កម្ពុជា ។ លោក **Hidetoshi Nishimura** បានលើកឡើងពីសកម្មភាពការងារជាច្រើនដែល ERIA បានបំពេញកន្លងមក និងទិសដៅទៅថ្ងៃមុខ ដើម្បីសម្រេចនូវគោលដៅជាចំបងរបស់ខ្លួន ដែលរួមមាន:**ទី១**–សម្របសម្រួលការកសាងសហគមន៍សេដ្ឋកិច្ចអាស៊ាន **ទី២:** ចូលរួមជួយកាត់បន្ថយនូវគម្លាតអភិវឌ្ឍន៍នៃប្រទេសក្នុងតំបន់ និង **ទី៣:** គាំទ្រតួនាទីរបស់អាស៊ាន ដើម្បីជម្រុញកំលាំងសេដ្ឋកិច្ច ក្នុងការធ្វើសមាហរណកម្មក្នុងអាស៊ីបូព៌ា ។ ចំពោះវឌ្ឍនភាពនៃការងារស្រាវជ្រាវរបស់វិទ្យាស្ថាន លោក **Hidetoshi Nishimura** បានលើកឡើងនូវចំណុចទាក់ទងមួយចំនួន ដូចជា: បញ្ហាពង្រឹងដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) –ហេដ្ឋារចនាសម្ព័ន្ធ–ថាមពល និង បរិស្ថាន ជាដើម ។ ដោយឡែក ទាក់ទងនិងការអភិវឌ្ឍន៍វិស័យសហគ្រាសធន់តូច និងមធ្យម (SME) នៅក្នុងតំបន់អាស៊ាន លោកនាយកប្រតិបត្តិវិទ្យស្ថាន ERIA បានបញ្ជាក់ថា:កាលពីថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០១៤ កន្លងមកនេះ នៅទីក្រុងប៉ារីស ប្រទេស បារាំង ដែលមានខ្លួនលោកផ្ទាល់តំណាងឱ្យវិទ្យាស្ថាន ERIA បាន ចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ជាមួយលោក **Angel Gurria** អគ្គលេខាធិការ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ហៅកាត់ថា: OECD ដើម្បីអនុវត្តការស្រាវជ្រាវគោលនយោបាយរួម ស្តីអំពីបញ្ហាការពង្រីកកិច្ចសហប្រតិបត្តិការពហុវិស័យ ដែលរួមមាន:**ទី១:** គោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម និងការជម្រុញលើកទឹកចិត្តសហគ្រិន **ទី២:** ការវិនិយោគវិស័យហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការប្រើប្រាស់យន្តការដៃគូឯកជនសាធារណៈ(PPP) និង **ទី៣**–ធ្វើការវិភាគ ស្តីពីតម្លៃបន្ថែមក្នុងវិស័យពាណិជ្ជកម្ម និងតម្លៃខ្សែសង្វាក់ផលិតកម្មសកល ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងារ និងបេសកកម្មរបស់វិទ្យស្ថាន ERIA ក្នុងប្រតិបត្តិការស្រាវជ្រាវរបស់ខ្លួន ហើយបានស្តែងចេញជារបាយការណ៍ សម្រាប់ជាមូលដ្ឋាន ពិនិត្យ ពិចារណា ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍នីមួយៗ។ ទាក់ទង និងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងវិទ្យាស្ថាន ERIA និង អង្គការ OECD ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរ និងវាយតម្លៃខ្ពស់ ព្រមទាំងឱ្យស្នើឱ្យវិទ្យាស្ថាន ERIA ផ្ញើរបាយការណ៍ស្រាវជ្រាវ និងឯកសារពាក់ព័ន្ធមកក្រសួងឧស្សាហកម្ម និង

សិប្បកម្មដើម្បីសិក្សាស្វែងយល់ ហើយក្រសួងគាំទ្រជានិច្ច រាល់កិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថាន ERIA ក្នុងន័យសហការរួមចំណែកអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា ដែលមានជាង៥សែនមូលដ្ឋាន ឱ្យមានឧត្តមភាពប្រកួតប្រជែងខ្ពស់។